**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា**
**ប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា**
**នៅទីក្រុងហ្សឺណែវ**

**សេចក្តីប្រកាសព័ត៌មាន**

## "សិទ្ធិមនុស្សជាច្រើននៅកម្ពុជាត្រូវបានលើកសរសើរ ក្នុងកិច្ចពិភាក្សារបស់អង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ"

*ទីក្រុងហ្សឺណែវ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣* - គណៈប្រតិភូសរុបចំនួន៣២ ប្រទេស បានចូលរួមកិច្ចសន្ទនាអន្តរសកម្មជាមួយអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៩ និងទី១០ ខែតុលា ឆ្នាំ២០២៣ អំឡុងសម័យប្រជុំលើកទី៥៤ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស នាទីក្រុងហ្សឺណែវ។

ក្រុមប្រឹក្សាសិទ្ធិមនុស្សបានឮយ៉ាងកងរំពងនូវការសម្តែងការកោតសរសើរនិងទទួលស្គាល់ជាទូទៅរបស់គណប្រតិភូ លើសមិទ្ធិផលសម្រេចបានគួរឱ្យកត់សម្គាល់ក្នុងសិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌ ព្រមទាំងកិច្ចសហប្រតិបត្តិការរបស់កម្ពុជាជាមួយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិជាច្រើន រួមទាំងការអនុញ្ញាតឱ្យមានទស្សនកិច្ចដោយគ្មានការរារាំង ការធ្វើការជាមួយ និងការបន្តអាណត្តិអ្នករាយការណ៍ពិសេសនៅកម្ពុជា។

គណៈប្រតិភូចំនួន២៣ បានថ្លែងគាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែង វឌ្ឍនភាព និងសមិទ្ធិផល ដែលកម្ពុជា សម្រេចបានក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍជាតិលើទិដ្ឋភាពជាច្រើន ព្រមទាំងបានអំពាវនាវឱ្យអ្នករាយការណ៍ពិសេស ប្រកាន់យកវិធីសាស្ត្រការងារប្រកបដោយតុល្យភាពនិងស្ថាបនា ដោយពិចារណាផងដែរចំពោះទស្សនទានរបស់រដ្ឋាភិបាល និងកាលៈទេសៈរបស់ប្រទេស។ កម្ពុជាទទួលបានការកោតសរសើរលើភាពជោគជ័យនៃការបោះឆ្នោតសកលឆ្នាំ២០២៣ ដោយវត្តមានអ្នកទៅបោះឆ្នោតខ្ពស់រហូតដល់ជាង ៨៤.៥៩ % ដើម្បីជ្រើសរើសគណបក្សនយោបាយមួយ ក្នុងចំណោមគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងចំនួន១៨ ប្រព្រឹត្តទៅក្នុងបរិយាកាស សេរី ត្រឹមត្រូវ មានតម្លាភាព គួរជាទីជឿទុកចិត្ត និងយុត្តិធម៌។ គណៈប្រតិភូបានថ្លែងកោតសរសើរ ក្នុងនោះរួមមាន ការឆ្លើយតបដោយជោគជ័យទៅនឹងជំងឺរាតត្បាតកូវីដ-១៩ ការងើបឡើងនូវសេដ្ឋកិច្ចក្រោយជំងឺរាតត្បាត ការផ្តួចផ្តើមកម្មវិធីគាំពារសង្គមជាច្រើន រួមទាំងកិច្ចដំណើការមូលនិធិជាតិជំនួយសង្គម ជួយដល់គ្រួសារក្រីក្រនិងងាយរងគ្រោះ សិទ្ធិជនជាតិ

អាសយដ្ឋាន៖ 3 Chemin Taverney, P.O. Box 213
1218 Grand-Saconnex, Geneva, Switzerland
ទូរស័ព្ទ៖ (៤១) ២២ ៧៨៨ ៧៧ ៧៣
អ៊ីម៉ែល៖ camemb.gva@mfaic.gov.kh

ភាគតិច និងជនមានពិការភាព សេរីភាពសាសនា កំណើនអត្រាអក្ខរកម្ម កំណើនវិភាជថវិកាលើវិស័យសង្គមកិច្ច និងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ស្របតាមគោលការណ៍ទីក្រុងប៉ារីសក៏ត្រូវបានទទួលស្គាល់ផងដែរ។ គណប្រតិភូខ្លះបានទទួលស្គាល់វឌ្ឍនភាពនិងសមិទ្ធិផលសម្រេចបានរបស់កម្ពុជាលើការលើកកម្ពស់តួនាទីស្ត្រីក្នុងកិច្ចការមុខងារសាធារណៈ សន្តិភាពនិងសន្តិសុខ ការដោះមីន និងសហគ្រិនភាព ព្រមទាំងស្វាគមន៍វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ។ គណប្រតិភូខ្លះបានកត់សម្គាល់នូវភាពរស់រវើកនិងចំនួនដ៏ច្រើននៃអង្គភាពសារព័ត៌មាន អង្គការសង្គមស៊ីវិល និងសហជីព នៅកម្ពុជា។

ដោយឡែក គណៈប្រតិភូចំនួន ៩ ផ្សេងទៀត បានចូលរួមក្នុងកិច្ចពិភាក្សាខាងលើដោយបញ្ចេញមតិទិតៀន អំពាវនាវឱ្យកម្ពុជាលើកកម្ពស់លំហពលរដ្ឋនិងនយោបាយ រួមទាំងការគោរពបន្ថែមទៀតនូវសេរីភាពនៃការបញ្ចេញមតិ សារព័ត៌មាន និងការប្រមូលផ្តុំដោយសន្តិវិធី ព្រមទាំងឯករាជ្យភាពប្រព័ន្ធតុលាការ។ ទន្ទឹមនេះ គណៈប្រតិភូទាំងនោះស្ទើរទាំងអស់បានស្វាគមន៍កិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់របស់កម្ពុជា ជាមួយយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងវឌ្ឍនភាពសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ជាពិសេស កំណើនវិភាជថវិកាសម្រាប់វិស័យសង្គម និងអប់រំ និងសុខាភិបាល។ គណៈប្រតិភូទាំងនោះក៏បានកត់សម្គាល់ជាវិជ្ជមាននូវកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងប្រព័ន្ធគាំពារសង្គម និងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។

ក្នុងឱកាសនៃកិច្ចពិភាក្សានេះ ឯកអគ្គរាជទូតនិងតំណាងអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិនៅហ្សឺណែវ បានគូសរំលេចនូវចន្លោះខ្វះខាតលើរបាយការណ៍របស់អ្នករាយការណ៍ពិសេស ដូចតទៅ៖

- យើងខ្ញុំសោកស្តាយដែលរបាយការណ៍នេះមិនបានឆ្លុះបញ្ចាំងនូវការពិតលើទិដ្ឋភាពជាច្រើន ដោយមិនលើកឱ្យមានតុល្យភាពនិងពេញលេញ នូវអង្គហេតុនិងអង្គច្បាប់ ដែលផ្តល់ដោយស្ថាប័នជាច្រើនរបស់រដ្ឋ។ ការអនុវត្តបែបនេះវៀចចាកពីគោលការណ៍ដែលបានកំណត់យ៉ាងច្បាស់ក្នុង "ក្រមប្រតិបត្តិ" និង "សៀវភៅប្រតិបត្តិការរបស់អ្នកកាន់អាណត្តិនីតិវិធីពិសេស" ជាហេតុបណ្តាលឱ្យមានការដាក់ពិន្ទុខុសឆ្គង និងវាយតម្លៃយ៉ាងអយុត្តិធម៌លើទិដ្ឋភាពសិទ្ធិពលរដ្ឋនិងនយោបាយ។
- និយាមដែលបានស្នើ ពុំឆ្លុះបញ្ចាំងនូវកិច្ចខិតខំប្រឹងប្រែងនិងវឌ្ឍនភាពឥតឈប់ឈរជាច្រើន រួមទាំងបរិយាកាសជុំវិញការបោះឆ្នោត ការផ្តល់និតីសម្បទាសិទ្ធិនយោបាយឡើងវិញដល់ក្រុមប្រឆាំង កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ និងការបង្ក្រាបការជួញដូរមនុស្ស ។ល។

ឯកអគ្គរាជទូតកម្ពុជាក៏ថ្លែងតបជាមួយនឹងអ្នករាយការណ៍ពិសេស លើប្រធានបទមួយចំនួនដទៃទៀតផងដែរ ដូចខាងក្រោម៖

- ក្នុងដំណើរឆ្ពោះទៅការបោះឆ្នោតឃុំសង្កាត់ និងសភា ក្នុងឆ្នាំ២០២២ និង២០២៣ លំហពលរដ្ឋនិងនយោបាយត្រូវបានពង្រីក។ ក្នុងនោះ បម្រាមសកម្មនយោបាយរបស់បុគ្គលជាង១០០ នាក់ ក្នុងចំណោមទណ្ឌិតដែលជាប់ពាក់ព័ន្ធនឹងការបង្ករអសន្តិសុខជាតិ ត្រូវបានរំសាយបញ្ចប់។ ពួកគេបានបង្កើតនិងចូលរួមគណបក្សនយោបាយផ្សេងៗដើម្បីប្រកួតប្រជែងក្នុងការបោះឆ្នោតថ្មីៗនេះ។ ទណ្ឌិតប្រមាណ៣០ រូប បានទទួលការលើកលែងទោស និងទទួលបានសិទ្ធិធ្វើនយោបាយឡើងវិញ។
- ការបោះឆ្នោតសកលនាពេលថ្មីៗនេះមានអត្រាវត្តមានអ្នកចូលរួមបោះឆ្នោតខ្ពស់រហូតដល់ ៨៤,៥៩% ដើម្បីជ្រើសរើសគណបក្សនយោបាយមួយក្នុងចំណោមគណបក្សនយោបាយចូលរួមប្រកួតប្រជែងចំនួន១៨ និងមេដឹកនាំអនាគត ដែលប្រជាជនជឿជាក់ថា អាចបន្តដឹកនាំជាតិលើមាគ៌ាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ កិច្ចដំណើរការបោះឆ្នោតត្រូវបានឃ្លាំមើលយ៉ាងជិតដល់ពីសំណាក់អ្នកសង្កេតការណ៍ឯករាជ្យជាតិនិងអន្តរជាតិជិតមួយពាន់នាក់ ដែលបានវាយតម្លៃយ៉ាងទូលំទូលាយ ថាការបោះឆ្នោតបានប្រព្រឹត្តិទៅដោយសេរី ត្រឹមយុត្តិធម៌ និងដោយសន្តិវិធី។ ការផ្ទេរអំណាចត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន តាមដំណើរប្រជាធិបតយ្យេប្រកបដោយភាពហ្មត់ចត់ ទាំងក្នុងកម្រិតគណបក្ស ការបោះឆ្នោត និងសភា។
- អវត្តមានគណបក្សនយោបាយចំនួនពីរក្នុងដំណើរការបោះឆ្នោត ដោយសារការមិនគោរពតាមច្បាប់ មិនអាចបដិសេធលក្ខណៈនៃសេរីភាព ពហុភាព និងប្រជាធិបតេយ្យរបស់កម្ពុជាបានឡើយ។ ដើម្បីធានាបរិយាកាសរស់រវើក និងប្រកបដោយក្តីស្ថាបនាសម្រាប់គណបក្សនយោបាយទាំងអស់ដែលមានបំណងចង់ចូលរួមជាមួយរដ្ឋាភិបាលថ្មី តាមរយៈការផ្តល់គំនិត និងការពិគ្រោះយោបល់ ឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់ជាន់ខ្ពស់ ត្រូវបានបង្កើតឱ្យដំណើរការឡើងវិញជាផ្លូវការ។ កន្លងមកនេះ គណបក្សនយោបាយចំនួន៣០ បានដាក់បេក្ខភាពជាសមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់ជាន់ខ្ពស់។
- ជាប្រការមិនអាចប្រកែកបានដែលលំហពលរដ្ឋនិងនយោបាយមានភាពសេរី និងបើកចំហរស្តែងឡើងតាមរយៈតួនាទីដ៏រស់រវើករបស់វត្តមានអង្គការមិនមែនរដ្ឋាភិបាលជាង៦០០០ និងអង្គភាពសារព័ត៌មានទាំងឌីជីថលនិងប្រពៃណីជាង២០០០ ប្រតិបត្តិការដោយគ្មានការរឹតត្បិត។ ជាងនេះទៅទៀត រដ្ឋាភិបាលនៅតែប្តេជ្ញាចិត្តបន្តវេទិកាសន្ទនាភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើឡើង ២ដង ក្នុងមួយឆ្នាំ ដើម្បីដោះស្រាយសេចក្តីព្រួយបារម្ភ រួមទាំងវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាបន្តបន្ទាប់។

- ឯករាជ្យភាពរបស់ប្រព័ន្ធតុលាការត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។ មានឧទាហរណ៍ជាច្រើន បង្ហាញថា អ្នកគាំទ្រនិងសមាជិកបក្សកាន់អំណាចក៏ត្រូវបានកាត់ទោសដោយតុលាការតែមួយដូចគ្នានោះ។ សម្ព័ន្ធភាពជាមួយគណបក្សនយោបាយ សហជីព ឬអង្គភាពដែលប្រកាសថាធ្វើការលើសិទ្ធិណាមួយនោះ ពុំមែនជាអាជ្ញាប័ណ្ណឱ្យបុគ្គលណាម្នាក់បំពានច្បាប់ដោយនិទណ្ឌភាពឡើយ។

តំណាងអចិន្ត្រៃយ៍កម្ពុជាបានថ្លែងបញ្ចប់ដោយគូសបញ្ជាក់នូវ ការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់កម្ពុជា ជាប្រទេសដែលបានផ្តល់សច្ចាប័នលើលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗស្ទើរតែទាំងអស់ ក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្សទៅតាមរដ្ឋធម្មនុញ្ញនិងនៅក្នុងក្របខណ្ឌនៃនីតិរដ្ឋ ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ថែរក្សាសន្តិភាពដែលសម្រេចបានដោយលំបាក និងដើម្បីបន្តដំណើរប្រជាធិបតេយ្យប្រកបដោយពហុនិយម ដោយឥតថយក្រោយ៕